# ស្ថានភាពទី ២ ៖ ឃ្លែរ—តើការខិតខំរបស់ខ្ញុំគ្រប់គ្រាន់ដើម្បីធ្វើអ្វី ដែលព្រះអម្ចាស់បានបង្គាប់ដល់ខ្ញុំដែរឬទេ ? ( យ៉ូហាន ៦:៥–១៤ )

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

នៅពេលដែលព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានឃើញហ្វូងមនុស្សកំពុងមកជិតនោះ ពួកសិស្សភ័យខ្លាចថា ពួកគេគ្មានអាហារគ្រប់គ្រាន់ដើម្បីឲ្យមនុស្សគ្រប់គ្នាបរិភោគ ។

សូមសិក្សាដំណើររឿងដែលព្រះយេស៊ូវបានប្រទានអាហារដល់មនុស្ស ៥០០០ នាក់នៅក្នុង យ៉ូហាន ៦:៥–១៤ ដោយស្វែងរក និងគូសចំណាំភស្តុតាងនៃគោលការណ៍នេះ ៖ **នៅពេលយើងថ្វាយដល់ព្រះអង្គសង្គ្រោះនូវអ្វីៗទាំងអស់ដែលយើងមាន នោះទ្រង់អាចបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីសម្រេចនូវព្រះរាជបំណងរបស់ទ្រង់** ។

- តើអ្នករកឃើញអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ដែលគាំទ្រដល់គោលការណ៍នេះ ?
- តើអ្នកគិតថា ពួកសិស្ស ឬក្មេងប្រុសរូបនោះមានអារម្មណ៍យ៉ាងណា ចំពោះអ្វីដែលពួកគេត្រូវផ្តល់ ប្រសិនបើប្រៀបធៀបទៅនឹងអ្វីដែលត្រូវការនោះ ?

សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយស៊ិស្ទើរ មីឆែល ឌី ក្រេហ្គ ទីប្រឹក្សាទីមួយក្នុងគណៈប្រធានយុវនារីទូទៅ ៖



> តើបងប្អូនធ្លាប់មានអារម្មណ៍ថា ទេពកោសល្យ និងអំណោយទានរបស់បងប្អូនគឺតិចតួចណាស់សម្រាប់កិច្ចការដែលនៅខាងមុខដែរឬទេ ? ខ្ញុំធ្លាប់មានអារម្មណ៍បែបនោះ ។ ប៉ុន្តែបងប្អូន និងខ្ញុំអាចថ្វាយអ្វីដែលយើងមានជូនដល់ព្រះគ្រីស្ទ ហើយទ្រង់នឹងបង្កើនការខិតខំរបស់យើង ។ អ្វីដែលបងប្អូនមានគឺលើសពីគ្រប់គ្រាន់ទៅទៀត—សូម្បីតែជាមួយគុណវិបត្តិ និងភាពទន់ខ្សោយជាមនុស្សរបស់បងប្អូនក្តី—*ប្រសិនបើ* បងប្អូនពឹងផ្អែកលើព្រះគុណនៃព្រះនោះ ។ ( មីឆែល ឌី ក្រេហ្គ « Divine Discontent » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៥៤ )

- តើវិធីខុសៗគ្នាអ្វីខ្លះដែលយើងអាច « ថ្វាយអ្វីដែលយើងមានដល់ព្រះគ្រីស្ទ ? »
- តើអ្នកបានរៀនអ្វីខ្លះ ចេញពីដំណើររឿងរបស់ព្រះយេស៊ូវដែលប្រទានអាហារដល់មនុស្ស ៥០០០ នាក់នេះ ដែលអាចជួយដល់នរណាម្នាក់ដែលមានការព្រួយបារម្ភថា អ្វីៗដែលពួកគេអាចផ្តល់ឲ្យ នឹងមិនគ្រប់គ្រាន់ឡើយ?

នៅពេលអ្នករៀបចំចែកចាយនូវអ្វីដែលអ្នកបានរៀន សូមគិតពីឧទាហរណ៍ក្នុងជីវិតរបស់អ្នក ឬក្នុងជីវិតរបស់មនុស្សដទៃ នៅពេលអ្នកបានឃើញព្រះអង្គសង្គ្រោះបង្កើនការខិតខំរបស់នរណាម្នាក់ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់នោះ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *Scenario 2: Claire* ។
Cambodian ។ PD60012661 258. Printed in the United States of America.